MEKONG RIVER COMMISSION
MRC
FOR SUSTAINABLE DEVELOPMENT

សេចក្តីណែនាំអំពី

# វិធាននីតិវិធីរបស់គណៈកម្មការទន្លេមេគង្គ

សម្រាប់

# កិច្ចសហប្រតិបត្តិការស្តីពីធនធានទឹកទន្លេមេគង្គ



PDIES

PWUM

PNPCA

PMFM

PWQ


អាងទន្លេមេគង្គ
អាងទន្លេមេគង្គលើ
ចិន
មីយ៉ាន់ម៉ា
ហាណូយ
ឡាវ
វៀងច័ន្ទ
អាងទន្លេ
មេគង្គក្រោម
ទន្លេមេគង្គ
ថៃ
វៀតណាម
បាងកក
ភ្នំពេញ
កម្ពុជា
ជ

# កិច្ចសហប្រតិបត្តិការស្តីពីធនធានទឹក សម្រាប់ការអភិវឌ្ឍអាងទន្លេមេគង្គ ប្រកបដោយចីរភាព

ទន្លេមេគង្គគឺជាទន្លេមួយក្នុងចំណោមទន្លេធំៗជាងគេរបស់ពិភពលោក ដែលមានប្រវែង ៤.៩០០ គីឡូម៉ែត្រ ហូរកាត់ប្រទេស ចំនួនប្រាំមួយ៖ ចិន មីយ៉ានម៉ា ថៃ ឡាវ កម្ពុជា និងវៀតណាម។ ទន្លេនេះ ល្បីល្បាញដោយសារជីវចម្រុះដ៏សម្បូរបែប និងសម្បូរដោយធនធានធម្មជាតិ ដែលជួយទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជាង ៦៥ លាននាក់ ដែលរស់នៅក្នុងតំបន់អាងទន្លេមេគង្គក្រោម។ មានឈ្មោះជា "មាតាទន្លេ" ទន្លេនេះ ផ្តល់នូវសក្តានុពលយ៉ាងធំធេង សម្រាប់ការអភិវឌ្ឍតំបន់នេះ។

ទោះជាយ៉ាងណាក៏ដោយ កំណើនចំនួនប្រជាជនយ៉ាងឆាប់រហ័ស ការបង្កើនល្បឿននៃការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធទឹក គ្រោះមហន្តរាយធម្មជាតិធ្ងន់ធ្ងរ ដែលកើតឡើងដោយសារសកម្មភាពមនុស្សផង និងការប្រែប្រួលអាកាសធាតុផង បានបង្កការគំរាមកំហែងធ្ងន់ធ្ងរដល់ការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹកក្នុងទន្លេមេគង្គ។

នៅក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ពោលចាប់តាំងពីទសវត្សរ៍ ១៩៥០ មក ប្រទេសទាំងបួនដែលស្ថិតនៅតំបន់អាងទន្លេមេគង្គក្រោម គឺ កម្ពុជា ឡាវ ថៃ និងវៀតណាម បាន និងកំពុងធ្វើការងាររួមគ្នា ដើម្បីដោះស្រាយបញ្ហាប្រឈមនានា។ ក្នុងឆ្នាំ ១៩៩៥ ប្រទេសទាំងនេះបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការលើបញ្ហាធនធានទឹកក្នុងតំបន់ និងបានបង្កើតគណៈកម្មការទន្លេមេគង្គ (ហៅកាត់ថា MRC) ដើម្បីរួមគ្នាគ្រប់គ្រងធនធានទឹករួម ឱ្យកាន់តែមាននិរន្តរភាព និងសមធម៌ បន្ថែមទៀត។

ចាប់តាំងពីពេលនោះមក MRC បានក្លាយជាវេទិកាមួយ សម្រាប់ដំណោះស្រាយការទូតក្នុងវិស័យធនធានទឹក ដើម្បីឱ្យប្រទេសទាំងបួនសហការគ្នាយ៉ាងជិតស្និទ្ធ ក្នុងការលើកកម្ពស់ការប្រើប្រាស់ធនធានទឹក បើទោះបីជាប្រទេសទាំងនេះមានផលប្រយោជន៍ជាតិ និងអាទិភាពអភិវឌ្ឍន៍ខុសៗគ្នាយ៉ាងណាក៏ដោយ។ ដោយមាននាទីជាមជ្ឈមណ្ឌលចំណេះដឹងផង គណៈកម្មការនេះ បានប្រមូលផ្តុំ និង ចែករំលែកចំណេះដឹងវិទ្យាសាស្ត្រ និងជំនាញបច្ចេកទេសយ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងវិស័យនានាពាក់ព័ន្ធនឹងធនធានទឹក ដូចជា វិស័យនេសាទ ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត និងនាវាចរណ៍ ដើម្បីគាំទ្រឱ្យមានការរៀបចំផែនការអភិវឌ្ឍន៍តំបន់អាងទន្លេឱ្យកាន់តែល្អប្រសើរឡើង។

# កិច្ចព្រមព្រៀងមេគង្គ និងនីតិវិធីរបស់ MRC កំណត់ក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ

កិច្ចព្រមព្រៀងមេគង្គឆ្នាំ ១៩៩៥ ដាក់ចេញនូវក្របខ័ណ្ឌច្បាប់ ដើម្បីឱ្យប្រទេសទាំងបួនសហការគ្នាអភិវឌ្ឍន៍ និងគ្រប់គ្រងធនធានទឹកឱ្យរឹតតែល្អប្រសើរបន្ថែមទៀត ដើម្បីនាំមកនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ហើយទន្ទឹមគ្នាដើម្បីការពារបរិស្ថាន។ កិច្ចព្រមព្រៀងនេះ ដាក់ចេញនូវបេសកកម្ម និងគោលដៅរបស់ស្ថាប័ននេះ និងបានកំណត់ពីតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នទាំងបី គឺ ក្រុមប្រឹក្សា គណៈកម្មាធិការរួម និងលេខាធិការដ្ឋាន ព្រមទាំងគោលបំណងជាយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការ។ ចុងក្រោយ កិច្ចព្រមព្រៀងនេះ បានប្រគល់ភារកិច្ចឱ្យ MRC លើកកម្ពស់ការប្រើប្រាស់ទឹកឱ្យបានល្អប្រសើរ និងជានានូវការអភិវឌ្ឍតំបន់អាងទន្លេនេះប្រកបដោយតុល្យភាពនិងគាំទ្រដល់ការសម្រេចបានសក្តានុពលពេញលេញនៃទន្លេមេគង្គ តាមរយៈការដាក់ចេញនូវផែនការអភិវឌ្ឍន៍អាងទន្លេ។

ជាច្រើនឆ្នាំកន្លងមកនេះ MRC និងប្រទេសជាសមាជិកបានរៀបចំនូវវិធាននីតិវិធីចំនួនប្រាំ និងគោលការណ៍ណែនាំបច្ចេកទេសពាក់ព័ន្ធ ស្តីពីការចែករំលែកទិន្នន័យ ការពិនិត្យតាមដានការប្រើប្រាស់ទឹក កិច្ចសហប្រតិបត្តិការក្នុងការប្រើប្រាស់ទឹក ការរក្សាលំហូរទឹក និងគុណភាពទឹក។ វិធាននីតិវិធីបីដំបូង កំណត់ពីដំណើរការសម្រាប់កិច្ចសហប្រតិបត្តិការលើធនធានទឹក ខណៈដែលវិធាននីតិវិធី ដែលនៅសល់ផ្សេងទៀត កំណត់ពីលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃស្ថានភាពទឹក។ វិធានទាំងនេះ ដែលហៅថា នីតិវិធីរបស់ MRC គឺជាឧបករណ៍រួម ដែលមានលក្ខណៈជាប្រព័ន្ធ សម្រាប់អនុវត្តកិច្ចព្រមព្រៀងមេគង្គ។






វិធាននីតិវិធីទាំងប្រាំ មានដូចតទៅ៖

**PDIES**

នីតិវិធីសម្រាប់ការដោះដូរ និងការចែករំលែកទិន្នន័យ និងព័ត៌មាន (PDIES) ត្រូវបានអនុម័តក្នុងឆ្នាំ ២០០១ ដើម្បីដោះដូរទិន្នន័យ និងព័ត៌មានជុំវិញសូចនាករសំខាន់ៗពាក់ព័ន្ធនឹងទឹក ក្នុងចំណោមប្រទេសជាប់ទន្លេមេគង្គទាំងបួន។

**PWUM**

នីតិវិធីសម្រាប់ការពិនិត្យតាមដានការប្រើប្រាស់ទឹក (PWUM) ត្រូវបានអនុម័តក្នុងឆ្នាំ ២០០៣ ដើម្បីបង្កើតនូវប្រព័ន្ធពិនិត្យតាមដានការប្រើប្រាស់ទឹកក្នុងទន្លេមេគង្គ និងដៃទន្លេក្នុងវិស័យផ្សេងៗប្រកបដោយប្រសិទ្ធភាព ដូចជា ការផ្គត់ផ្គង់ទឹកក្នុងប្រទេស ធារាសាស្ត្រ និងវារីអគ្គិសនីជាដើម។

**PNPCA**

នីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង (PNPCA) ត្រូវបានអនុម័តក្នុងឆ្នាំ ២០០៣ ដើម្បីសម្រួលដល់កិច្ចសហប្រតិបត្តិការជុំវិញការប្រើប្រាស់ទឹក និងការអភិវឌ្ឍ ដោយបានដាក់ចេញនូវដំណើរការដាក់លាក់ចំនួនបី សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធទឹក ដែលត្រូវបានស្នើឡើង។

**PMFM**

នីតិវិធីសម្រាប់រក្សាលំហូរទឹកលើទន្លេមេ (PMFM) ត្រូវបានអនុម័តក្នុងឆ្នាំ ២០០៦ ដើម្បីដាក់ចេញនូវលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃ និងដំណើរការពិនិត្យតាមដាន និងរក្សាលំហូរទឹកឱ្យបានគ្រប់គ្រាន់ក្នុងទន្លេមេគង្គ និងទន្លេសាប។

**PWQ**

នីតិវិធីសម្រាប់គុណភាពទឹក (PWQ) ត្រូវបានអនុម័តក្នុងឆ្នាំ ២០១១ ដើម្បីពង្រឹងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ សម្រាប់ពិនិត្យតាមដាន និងការពារគុណភាពទឹកក្នុងទន្លេមេគង្គ និងទន្លេបាសាក់ ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃដែលបានព្រមព្រៀងគ្នា។

សៀវភៅនេះពន្យល់ពីវិធាននីតិវិធីទាំងប្រាំ ដោយប្រើប្រាស់ភាសាសាមញ្ញ និងបង្ហាញឱ្យឃើញថា វិធាននីតិវិធីទាំងនេះ មានសារៈសំខាន់យ៉ាងខ្លាំង សម្រាប់កិច្ចសហប្រតិបត្តិការទឹកនៅថ្នាក់តំបន់ ក៏ដូចជាការគ្រប់គ្រង និងការអភិវឌ្ឍតំបន់អាងទន្លេនេះ ប្រកបដោយចីរភាព។

## កសាងមូលដ្ឋានគ្រឹះសម្រាប់ការចែករំលែកទិន្នន័យក្នុងតំបន់

ការគ្រប់គ្រងធនធានទឹកឆ្លងដែនក្នុងតំបន់មេគង្គ ពឹងអាស្រ័យយ៉ាងខ្លាំង លើភាពអាចរកបាននូវទិន្នន័យ និងព័ត៌មាន ដែលអាចជឿទុកចិត្តបាន អំពីវិស័យនានា។ រាប់តាំងពីវិស័យជលផល ជលសាស្ត្រ រហូតដល់គុណភាពទឹក ទិន្នន័យដែលប្រមូលបានពីតំបន់អាងទន្លេទាំងមូល មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីឱ្យគេអាចយល់ដឹងកាន់តែច្បាស់ពីស្ថានភាពរបស់អាងទន្លេនេះ។ យ៉ាងណាក៏ដោយ ការប្រមូលទិន្នន័យអំពីបាតុភូតឆ្លងដែន គឺជាការលំបាក ដោយហេតុថាប្រទេសនានា ជាធម្មតា ដាក់កម្រិតលើការចែករំលែកទិន្នន័យក្នុងស្រុក ជាមួយប្រទេសផ្សេងទៀត ដោយសារតែមូលហេតុសន្តិសុខជាតិ និងមូលហេតុផ្សេងទៀត។

ដើម្បីសម្រួលឱ្យមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ក្នុងការដោះដូរទិន្នន័យ MRC និង ប្រទេសជាសមាជិកបានរៀបចំនីតិវិធីសម្រាប់ការដោះដូរ និងការចែករំលែកទិន្នន័យ និងព័ត៌មាន (ដែលហៅកាត់ថា PDIES) ដែលបានដាក់ចេញនូវក្របខ័ណ្ឌ ដើម្បីឱ្យប្រទេសជាប់ទន្លេមេគង្គចែករំលែកទិន្នន័យក្នុងតំបន់ ដើម្បីឱ្យការគ្រប់គ្រងធនធានទឹកកាន់តែមានភាពល្អប្រសើរជាងមុន។ អនុម័តក្នុងខែ វិច្ឆិកា ឆ្នាំ ២០០១ នីតិវិធីសម្រាប់ការដោះដូរ និងការចែករំលែកទិន្នន័យ និងព័ត៌មាននេះ បានក្លាយជាវិធានដំបូងគេ សម្រាប់គាំទ្រដល់កិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាលនៃប្រទេសទាំងបួនតាមដងទន្លេមេគង្គ។



## នីតិវិធីសម្រាប់ការដោះដូរ និងការចែករំលែកទិន្នន័យ និងព័ត៌មាន ពង្រឹងការគ្រប់គ្រងទិន្នន័យ ក្នុងតំបន់អាងទន្លេទាំងមូល

នីតិវិធីសម្រាប់ការដោះដូរ និងការចែករំលែកទិន្នន័យ និងព័ត៌មាន ព្រមទាំងគោលការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធ កំណត់ពីវិសាលភាពនៃការគ្រប់គ្រងទិន្នន័យក្នុងតំបន់ កំណត់ពីតួនាទី និង ការទទួលខុសត្រូវរបស់ MRC និងប្រទេសជាសមាជិក ព្រមទាំងកំណត់ទម្រង់នៃការប្រមូល ការរក្សាទុក និងការផ្សព្វផ្សាយទិន្នន័យ។ វិធានទាំងនេះ ត្រូវបានតាក់តែងឡើងដើម្បីពង្រឹងការគ្រប់គ្រងឆ្លងដែននូវព័ត៌មានដែលអាចជឿជាក់បាន។

ក្រោមនីតិវិធីនេះ ប្រទេសជាប់ទន្លេមេគង្គ ត្រូវប្រមូល និងចែករំលែកព័ត៌មាននានា ដូចជា ព័ត៌មានអំពីស្ថានភាពជលសាស្ត្រ ឧតុនិយម ឋានលេខាសាស្ត្រ ធារាសាស្ត្រ នាវាចរ ការគ្រប់គ្រងទឹកជំនន់ វារីអគ្គិសនី បរិស្ថាន សង្គម សេដ្ឋកិច្ច និងទេសចរណ៍ និងព័ត៌មានផ្សេងទៀត។ ទិន្នន័យទាំងនេះ ត្រូវចែករំលែកជាមួយលេខាធិការដ្ឋាន MRC សម្រាប់បូកសរុប វិភាគ និងផ្សព្វផ្សាយជាសាធារណៈ។




ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ MRC បានប្រមូលផ្តុំទិន្នន័យ និងព័ត៌មានយ៉ាងច្រើន ដែលមានសារៈសំខាន់សម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍតំបន់អាងទន្លេនេះ ប្រកបដោយចីរភាព ដូចជា ទិន្នន័យច្រើនឆ្នាំតាំងពីឆ្នាំ ១៩០០ និងទិន្នន័យថ្មីៗអំពីវិស័យផ្សេងៗ ដែលពាក់ព័ន្ធនឹងទឹក។ ការប្រមូលទិន្នន័យទាំងនេះធ្វើឡើងតាមរយៈបណ្តាញពិនិត្យតាមដានជាច្រើន ដូចជា ស្ថានីយជលសាស្ត្រ ឧតុនិយមស្វ័យប្រវត្តិចំនួន ៤៥ ស្ថានីយបែបប្រពៃណីចំនួន ១៣៩ សម្រាប់ពិនិត្យតាមដានកម្ពស់ទឹកភ្លៀង ឬកម្ពស់ទឹក ស្ថានីយប្រមូលសំណាកដើម្បីវាយតម្លៃគុណភាពទឹកចំនួន ៤៨ និងទីតាំងពិនិត្យតាមដានធនធានជលផលជាង ១០០ កន្លែង។

## នីតិវិធីសម្រាប់ការដោះដូរ និងការចែករំលែកទិន្នន័យ និងព័ត៌មាន នាំឱ្យការទទួលបានព័ត៌មានសំខាន់ៗរឹតតែមានភាពងាយស្រួល

ការចូលមើលទិន្នន័យដែលវិភាគរួច កាន់តែមានភាពងាយស្រួល តាមរយៈវេទិកាគ្រប់គ្រងទិន្នន័យ និងចែករំលែកទិន្នន័យជាច្រើនក្នុងក្របខ័ណ្ឌនៃប្រព័ន្ធព័ត៌មានរបស់ MRC។ ប្រកសំខាន់ជាងគេសម្រាប់ទិន្នន័យបច្ចេកទេសគឺ ផតថលសេវាទិន្នន័យ និងព័ត៌មាន ឬដែលហៅសាមញ្ញថា ផតថលទិន្នន័យ (Data Portal) ដែលផ្តល់លទ្ធភាពឱ្យអ្នកប្រើប្រាស់ពិនិត្យមើលកាតាឡុកចម្បង និងអាចស្វែងរកស្រាវជ្រាវ និងដោនឡូតទិន្នន័យនានា អំពីស្ថានភាពជលសាស្ត្រ ការព្យាករណ៍ទឹកជំនន់ គុណភាពទឹក ការប្រែប្រួលអាកាសធាតុ និងទិន្នន័យផ្សេងទៀត។ ប្រព័ន្ធទិន្នន័យតាមវិស័យ ដូចជា ធារាសាស្ត្រ វារីអគ្គិសនី និងសូចនាករសង្គម សេដ្ឋកិច្ច ក៏អាចរកបានតាមប្រព័ន្ធអនឡាន សម្រាប់អ្នកប្រើប្រាស់ខាងក្នុងស្ថាប័ន និងអ្នកប្រើប្រាស់ពីខាងក្រៅផងដែរ។

ឧទាហរណ៍ នៅលើផតថលទិន្នន័យ អ្នកចូលមើលអាចមើលឃើញកម្ពស់ទឹកប្រចាំថ្ងៃ ឬប្រចាំសប្តាហ៍នៅតាមស្ថានីយជលសាស្ត្រនានាក្នុងទន្លេមេគង្គនៅលើផែនទីបែបអន្តរកាល និងអាចពិនិត្យមើលរបាយការណ៍ស្ថានភាពទឹកជំនន់ប្រចាំសប្តាហ៍ ចាប់ពីឆ្នាំ ២០០៨ រៀងមក ក្នុង គេហទំព័រព្យាករណ៍កម្ពស់ទឹកជំនន់។

**ផតថលទិន្នន័យ - ផែនទីអន្តរកម្មស្តីពីស្ថានភាពអាកាសធាតុ**




*http://portal.mrcmekong.org/interactive-climate-change-atlas*

ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុវិញ ផែនទីអន្តរកម្ម ដែលបង្ហាញពីស្ថានភាពនៃការប្រែប្រួលអាកាសធាតុចុងក្រោយគេ ផ្តល់លទ្ធភាពឱ្យអ្នកប្រើប្រាស់ស្រាវជ្រាវពីប៉ារ៉ាម៉ែត្រអាកាសធាតុនានា ដូចជាកម្ពស់ទឹកភ្លៀង និងសីតុណ្ហភាពជាមធ្យមលើផែនទីដែលមានលក្ខណៈអន្តរកម្ម និងអាចឃើញការវាយតម្លៃលើផលប៉ះពាល់ដែលបង្កឡើងដោយសារការប្រែប្រួលអាកាសធាតុ ជុំវិញសេនារីយ៉ូផ្សេងៗនាពេលអនាគត។

គិតរហូតដល់ពេលបច្ចុប្បន្ននេះ ផតថលទិន្នន័យនេះមានអ្នកប្រើប្រាស់ ដែលបានចុះឈ្មោះជាង ៧០០នាក់ ដែលក្នុងនោះមាន អ្នកតាក់តែងគោលនយោបាយ អ្នកជំនាញ អ្នកប្រើប្រាស់ជាលក្ខណៈពាណិជ្ជកម្ម អ្នកស្រាវជ្រាវ និងសិស្ស និស្សិត ដែលតែងចូលទៅក្នុងប្រព័ន្ធទិន្នន័យរបស់ MRC ជាញឹកញាប់។ ក្នុងឆ្នាំ ២០១៧ មានអ្នកចូលមើលទិន្នន័យជាង ៤0.000 នាក់ មកពីជាង ៣0 ប្រទេស បានចូលមើលផតថលទិន្នន័យនេះ និងមានការស្នើសុំទិន្នន័យជាក់លាក់ចំនួន ៦៨៥ សំណើ។

ដោយឡែកពីប្រព័ន្ធទិន្នន័យបច្ចេកទេសទាំងនេះ គេក៏អាចរកបាននូវឯកសារចំណេះដឹង ក្នុងបរិមាណដ៏ច្រើន ដែលរៀបចំឡើងផ្អែកតាមការវិភាគទិន្នន័យ និងឯកសារអប់រំផ្សព្វផ្សាយផ្សេងទៀត អំពីស្ថានប័ននេះ ក្នុងគេហទំព័រផ្លូវការរបស់ MRC។ លើសពីនេះ MRC មានច្រកផ្តល់ព័ត៌មានពីរផ្សេងទៀត គឺ៖ MekongInfo ជាវេទិកាសម្រាប់បង្ហាញពីព័ត៌មាន និងឯកសារចំណេះដឹងពាក់ព័ន្ធនឹងទន្លេមេគង្គ ដែលមានប្រភពពីស្ថាប័នខាងក្រៅ និងវេទិកាសហគមន៍ ជាច្រកសម្រាប់ឱ្យអ្នកអនុវត្តការងារ និងអ្នកស្រាវជ្រាវពាក់ព័ន្ធនឹងទឹកធ្វើការប្រាស្រ័យទាក់ទង និងចែករំលែកបទពិសោធន៍ជាមួយគ្នា។

ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើនភាពងាយស្រួលដល់អ្នកប្រើប្រាស់ ក្នុងការចូលទៅមើលផតថលទិន្នន័យនេះ ក្នុងពេលឆាប់ៗនេះ MRC នឹងដាក់ឱ្យដំណើរការនូវ ប្រព័ន្ធគ្រប់គ្រងទិន្នន័យតាមពេលវេលា (time-series) ថ្មីមួយ ដើម្បីអនុញ្ញាតឱ្យអ្នកប្រើប្រាស់ងាយស្រួលមើលទិន្នន័យតាមពេលវេលា និងយកទិន្នន័យទាំងនេះទៅបំប្លែងជារូបភាពលើផែនទី និងដ្យាក្រាមដែលមានលក្ខណៈអន្តរកម្ម។ ប្រព័ន្ធថ្មីនេះ ក៏នឹងផ្តល់រូបភាព និងទិន្នន័យដែលទទួលបានពីផ្កាយរណបផងដែរ ដើម្បីបន្ថែមលើទិន្នន័យដែលប្រមូលបានពីមូលដ្ឋាន។ ប្រព័ន្ធព័ត៌មានថ្មីរបស់ MRC នេះ នឹងពង្រឹងតួនាទីរបស់ MRC ក្នុងនាមជាមជ្ឈមណ្ឌលចំណេះដឹង ដែលផ្តល់លទ្ធភាពឱ្យអ្នកស្រាវជ្រាវ និងអនុវត្តការងារ និងអ្នកតាក់តែងគោលនយោបាយ ទទួលបានទិន្នន័យវិទ្យាសាស្ត្រ និងកាន់តែស្រួលយល់ពីស្ថានភាពបច្ចុប្បន្នរបស់អាងទន្លេ និន្នាការ និងបញ្ហារសើបពាក់ព័ន្ធនឹងធនធានទឹក ព្រមទាំងផ្តល់នូវឱកាសបន្ថែមទៀត ដើម្បីឱ្យមានការសហការគ្នាជាមួយនឹងគ្រឹះស្ថាន និងស្ថាប័នស្រាវជ្រាវផ្សេងទៀត។

## គាំទ្រដល់ការប្រើប្រាស់ធនធានទឹកនាពេលអនាគត

ក្នុងតំបន់អាងទន្លេមេគង្គ ប្រជាពលរដ្ឋជនបទរាប់លាននាក់ ពឹងអាស្រ័យលើធនធានធម្មជាតិដ៏សម្បូរបែប ក្នុងតំបន់អាងទន្លេនេះ សម្រាប់សន្តិសុខស្បៀង និងការចិញ្ចឹមជីវិត ហើយទន្ទឹមគ្នានេះ រដ្ឋាភិបាល និងវិនិយោគិន តែងសម្លឹងរកឱកាសទាញប្រយោជន៍ពីសក្តានុពលរបស់តំបន់អាងទន្លេនេះ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងការបន្តកាត់បន្ថយភាពក្រីក្រ តាមរយៈគម្រោងហេដ្ឋារចនាសម្ព័ន្ធទឹកនានា ដូចជា វារីអគ្គិសនី ធារាសាស្ត្រ និងគ្រប់គ្រងទឹកជំនន់ជាដើម។ ដូច្នេះ ជាការសំខាន់ណាស់ ដែលត្រូវពិនិត្យតាមដានពីរបៀបដែលប្រទេសតាមដងទន្លេមេគង្គប្រើប្រាស់ធនធានទឹក ដើម្បីធានាបាននូវការអភិវឌ្ឍតំបន់អាងទន្លេនេះ ប្រកបដោយចីរភាព ព្រោះថា ទិន្នន័យស្តីពីការប្រើប្រាស់ទឹក នឹងផ្តល់នូវព័ត៌មានដ៏មានតម្លៃសម្រាប់ជួយដល់ការរៀបចំផែនការ និងការគ្រប់គ្រងតំបន់អាងទន្លេ។

ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមនេះ MRC និងប្រទេសជាប់ដងទន្លេមេគង្គទាំងបួន បានបង្កើតនីតិវិធីសម្រាប់ការពិនិត្យតាមដានការប្រើប្រាស់ទឹក (ដែលហៅកាត់ថា PWUM) ជាក្របខ័ណ្ឌមួយ ដើម្បីគាំទ្រដល់ប្រព័ន្ធដែលមានប្រសិទ្ធភាព សម្រាប់ពិនិត្យតាមដានការប្រើប្រាស់ធនធានទឹក ដែលអាចបង្កផលប៉ះពាល់គួរឱ្យកត់សម្គាល់ដល់ទន្លេមេ។ អនុម័តនៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៣ រួមគ្នាជាមួយនឹងនីតិវិធីសម្រាប់ជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង (PNPCA) នីតិវិធីនេះអំពាវនាវឱ្យមានការបង្កើតប្រព័ន្ធពិនិត្យតាមដានការប្រើប្រាស់ទឹក នៅដងទន្លេមេគង្គមេ និងដៃទន្លេសំខាន់ៗផ្សេងទៀត។



## នីតិវិធីសម្រាប់ការពិនិត្យតាមដានការប្រើប្រាស់ទឹក បង្កើតទិន្នន័យមូលដ្ឋានសម្រាប់ការអភិវឌ្ឍធនធានទឹក

នីតិវិធីសម្រាប់ការពិនិត្យតាមដានការប្រើប្រាស់ទឹក កំណត់ពីទំហំការងារ តួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នទាំងបីរបស់ MRC និងប្រទេសជាសមាជិក ព្រមទាំងគំរូសម្រាប់ពិនិត្យតាមដានការប្រើប្រាស់ធនធានទឹក។ ក្រោមនីតិវិធីសម្រាប់ការពិនិត្យតាមដានការប្រើប្រាស់ទឹកនេះ តម្រូវឱ្យមានការពិនិត្យតាមដានការប្រើប្រាស់ធនធានទឹក ក្នុងតំបន់អាងទន្លេមេគង្គ (ការប្រើប្រាស់ក្នុងអាងទន្លេ) និងរវាងអាងទន្លេមេគង្គ និងទន្លេណាមួយផ្សេងទៀត (ការបង្វែរទឹកពីតំបន់អាងទន្លេមួយទៅតំបន់អាងទន្លេមួយទៀត) និងផលប៉ះពាល់គួរឱ្យកត់សម្គាល់ ដែលអាចកើតមាន។ ខណៈដែលប្រទេសជាសមាជិកត្រូវប្រមូល និងផ្តត់ផ្គង់ទិន្នន័យពិនិត្យតាមដាន លេខាធិការដ្ឋាន MRC មានភារកិច្ចសរុបទិន្នន័យ រៀបចំរបាយការណ៍ និងផ្តល់អនុសាសន៍ ដើម្បីឱ្យការប្រើប្រាស់ធនធានទឹក កាន់តែប្រសើរជាងមុន។

ឯកសារណែនាំបច្ចេកទេសឆ្នាំ ២០០៦ ស្តីពីនីតិវិធីសម្រាប់ការពិនិត្យតាមដានការប្រើប្រាស់ទឹក តម្រូវឱ្យប្រទេសតាមដងទន្លេមេគង្គទាំងបួន កំណត់ជាបឋមនូវ ទិន្នន័យមូលដ្ឋានអំពីការប្រើប្រាស់ទឹកនាពេលបច្ចុប្បន្នតាមគម្រោងដែលមានស្រាប់ និងត្រូវកំណត់ពីសូចនាករសម្រាប់ពិនិត្យតាមដានការប្រើប្រាស់ទឹកក្នុងតំបន់អាងទន្លេ រួមនឹងទិន្នន័យកម្ពស់ទឹកភ្លៀង ប៉ារ៉ាម៉ែត្រគុណភាពទឹក និងប្រភេទនៃការប្រើប្រាស់ទឹក និងសូចនាករប្រភេទផ្សេងទៀត សម្រាប់ពិនិត្យតាមដានការបង្វែរទឹក ដូចជាទីតាំងនៃការបង្វែរទឹក សេចក្តីពិពណ៌នាសម្រាប់ការរៀបចំ និងបរិមាណទឹកដែលត្រូវបានបង្វែរចេញ។ ឯកសារណែនាំនេះ ក៏តម្រូវឱ្យមានការបង្កើតប្រព័ន្ធពិនិត្យតាមដានការប្រើប្រាស់ទឹកដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ក្នុងលេខាធិការដ្ឋាន MRC សម្រាប់បូកសរុបទិន្នន័យ និងរក្សាទុកទិន្នន័យផងដែរ។ ក្រោមក្របខ័ណ្ឌនេះ ចាំបាច់ត្រូវមានការពិនិត្យតាមដានការបង្វែរទឹកពីអាងទន្លេមួយទៅអាងទន្លេណាមួយផ្សេងទៀតជារៀងរាល់ថ្ងៃនៅរដូវប្រាំង និងយ៉ាងហោចណាស់រៀងរាល់សប្តាហ៍ក្នុងរដូវវស្សា។

ទោះជាយ៉ាងណាក៏ដោយ ចាប់តាំងពីមានការអនុម័តលើនីតិវិធី និងឯកសារណែនាំនេះរួចមក មានការធ្វើការងារជាក់ស្តែងតិចតួចប៉ុណ្ណោះ ដោយសារតែការលំបាកក្នុងការអនុវត្តនីតិវិធីនេះ។ ជាពិសេសគេមានការលំបាក ក្នុងការកត់ត្រាព័ត៌មានអំពីផលប៉ះពាល់របស់អ្នកប្រើប្រាស់ទឹកខ្នាតតូចជាច្រើននាក់ ដូចជា កសិករដែលប្រើប្រាស់ទឹកជាលក្ខណៈគ្រួសារ និងបង្កើតនូវប្រព័ន្ធពិនិត្យតាមដានការប្រើប្រាស់ទឹកក្នុងតំបន់ នៅពេលដែលពុំមានច្បាប់ជាតិស្តីពីប្រព័ន្ធសិទ្ធិពាក់ព័ន្ធនឹងទឹក ដូចជា លក្ខខណ្ឌតម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណ និងរៀបចំរបាយការណ៍ស្តីពីការប្រើប្រាស់ទឹកជាដើម។

# នីតិវិធីសម្រាប់ការពិនិត្យតាមដានការប្រើប្រាស់ទឹក ជំរុញឱ្យមានការអនុវត្តការពិនិត្យតាមដានសាកល្បង

បើទោះបីជាមានឧបសគ្គទាំងនេះក៏ដោយ MRC បានគាំទ្រដល់ប្រទេសជាសមាជិកនីមួយៗ ដើម្បីធ្វើការសិក្សាសាកល្បងលើការពិនិត្យតាមដានការប្រើប្រាស់ទឹក ដោយប្រទេសនីមួយៗត្រូវជ្រើសរើសតំបន់អាងទន្លេមួយ សម្រាប់ធ្វើការពិនិត្យតាមដានការប្រើប្រាស់ទឹកប្រភេទណាមួយក្នុងចំណោមការប្រើប្រាស់ទឹកទាំងបីប្រភេទគឺ ធារាសាស្ត្រ វារីអគ្គិសនី ឬការប្រើប្រាស់ទឹកតាមគ្រួសារ។ ប្រទេសកម្ពុជាកំណត់យកស្ទឹងពោធិ៍សាត់សម្រាប់ធ្វើការសិក្សាសាកល្បង ប្រទេសឡាវសាកល្បងនៅទន្លេសេដន ប្រទេសថៃសាកល្បងនៅទន្លេណាំកាំ និងប្រទេសវៀតណាមសាកល្បងនៅទន្លេស្រែពក។

ក្នុងអំឡុងពេលអនុវត្តសាកល្បងក្នុងឆ្នាំ ២០១៤-២០១៥ មានការប្រមូល និងផ្ទៀងផ្ទាត់ទិន្នន័យតាមប្រទេសនីមួយៗ ដោយប្រើប្រាស់ឧបករណ៍ និងវិធីសាស្ត្របង្កើតម៉ូដែល ដែលបានឯកភាពគ្នា។ ក្រុមដែលធ្វើការសិក្សាសាកល្បងនេះ បានកត់សម្គាល់ថា ទិន្នន័យអំពីការប្រើប្រាស់ទឹកមួយចំនួនងាយស្រួលរក ខណៈពេលដែលទិន្នន័យផ្សេងទៀត ពិបាកនឹងរក។ ពួកគេក៏រាយការណ៍ពីដែនកំណត់មួយចំនួននៃវិធីសាស្ត្រដែលប្រើប្រាស់សម្រាប់ការសាកល្បងនេះផងដែរ។

ដោយសារកំណែទម្រង់ស្ថាប័នរបស់ MRC ការងារពាក់ព័ន្ធនឹងនីតិវិធីសម្រាប់ការពិនិត្យតាមដានការប្រើប្រាស់ទឹកនេះ ត្រូវពន្យារពេលសម្រាប់ឆ្នាំ ២០១៦-២០១៧។ ក្រុមការងារបច្ចេកទេសថ្មីមួយត្រូវបានបង្កើតឡើងដើម្បីបញ្ចប់រាល់ការសិក្សាសាកល្បងទាំងអស់ ពិនិត្យឡើងវិញលើទិន្នន័យពិនិត្យតាមដានដែលបានពីការសិក្សា ពិនិត្យវិធីសាស្ត្រ និងឧបករណ៍ដែលត្រូវបានប្រើប្រាស់ក្នុងការសិក្សាដើម្បីប្រមូលមេរៀនបន្ថែមទៀត និងស្វែងយល់ពីវិធីសាស្ត្រដែលបានធ្វើតេស្ត សម្រាប់យកទៅអនុវត្តដើម្បីពិនិត្យតាមដានការប្រើប្រាស់ទឹកក្នុងតំបន់អាងទន្លេទាំងមូល។ នៅពេលដែលប្រព័ន្ធពិនិត្យតាមដានត្រូវបានបង្កើតឡើង ប្រព័ន្ធនេះនឹងផ្តល់ព័ត៌មានសំខាន់ៗ ដល់អ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នកប្រើប្រាស់ទឹក ដើម្បីឱ្យការរៀបចំផែនការ និងការគ្រប់គ្រងការអភិវឌ្ឍពាក់ព័ន្ធនឹងទឹកកាន់តែមានភាពល្អប្រសើរជាងមុន។





## ពង្រឹងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់លើការអភិវឌ្ឍធនធានទឹក

ជាការទាញប្រយោជន៍ពីសក្តានុពលទាំងមូលរបស់ទន្លេមេគង្គសម្រាប់ការអភិវឌ្ឍ ប្រទេសជាប់ដងទន្លេមេគង្គ បានចាប់ផ្តើមសាងសង់ស្ពាន សំណង់ជារាសាស្ត្រ និងសំណង់គ្រប់គ្រងទឹកជំនន់ទ្រង់ទ្រាយធំ និងទំនប់វារីអគ្គិសនីនៅតាមដងទន្លេមេ និងដៃទន្លេ។ គម្រោងទាំងនេះ នឹងនាំមកនូវអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចដល់មនុស្សជាច្រើននាក់ ប៉ុន្តែក៏អាចបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានឆ្លងដែន លើប្រព័ន្ធអេកូឡូស៊ី និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលពឹងអាស្រ័យលើទន្លេនេះផងដែរ។

ដើម្បីឱ្យមានតុល្យភាពរវាងការអភិវឌ្ឍ និងការការពារបរិស្ថាន MRC និងប្រទេសជាសមាជិកទាំងបួនបានបង្កើតនីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង (ហៅកាត់ថា PNPCA) ដែលបានបង្កើតនូវយន្តការសហប្រតិបត្តិការថ្នាក់តំបន់ សម្រាប់ការអភិវឌ្ឍធនជានទឹកដែលមានក្នុងផែនការ។ អនុម័តនៅក្នុងខែ វិច្ឆិកា ឆ្នាំ ២០០៣ នីតិវិធីនេះតម្រូវឱ្យប្រទេសជាសមាជិកដែលលើកស្នើគម្រោងហេដ្ឋារចនាសម្ព័ន្ធទឹកធំៗនៅតាមដងទន្លេមេគង្គ ឆ្លងកាត់ដំណើរការសហប្រតិបត្តិការជាក់លាក់ ដើម្បីធានាឱ្យមានការប្រើប្រាស់ធនជានទឹកប្រកបដោយចីរភាព និងសមធម៌ក្នុងតំបន់នេះ។

## នីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង មានដំណើរការចំនួនបី ដើម្បីសម្របសម្រួលកិច្ចការទូតផ្នែកធនជានទឹក

នីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង និងឯកសារណែនាំបច្ចេកទេសឆ្នាំ ២០០៥ នៃនីតិវិធីនេះ បានដាក់ចេញនូវដំណើរការជាក់លាក់ចំនួនបី ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការថ្នាក់តំបន់ក្នុងការអភិវឌ្ឍធនជានទឹក កត្តាកំណត់សម្រាប់ការអនុវត្តដំណើរការទាំងនេះ និងតួនាទីនិងការទទួលខុសត្រូវរបស់ប្រទេសស្នើសុំគម្រោង ប្រទេសដែលទទួលការជូនដំណឹង និងស្ថាប័នទាំងបីរបស់ MRC។ ក្រោមក្របខ័ណ្ឌនៃនីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង គម្រោងអភិវឌ្ឍន៍ធនជានទឹកទាំងឡាយក្នុងតំបន់នេះ ដែលអាចនាំឱ្យមានការផ្លាស់ប្តូរលំហូរ ឬគុណភាពទឹកក្នុងកម្រិតគួរឱ្យកត់សម្គាល់ក្នុងដងទន្លេមេត្រូវឆ្លងកាត់ដំណើរការមួយ ក្នុងចំណោមដំណើរការទាំងបីគឺ៖ ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន ឬកិច្ចព្រមព្រៀងជាក់លាក់។

**ការជូនដំណឹង** តម្រូវឱ្យប្រទេសដែលលើកស្នើគម្រោងផ្តល់ព័ត៌មានលម្អិតដល់ប្រទេសជាសមាជិកដទៃទៀត មុនពេលចាប់ផ្តើមប្រើប្រាស់ទឹក ដូចដែលបានលើកស្នើឡើង។

**ការពិគ្រោះយោបល់ជាមុន** គឺជាដំណើរការរយៈពេល ៦ខែ សម្រាប់ធ្វើការវាយតម្លៃបច្ចេកទេស និងរៀបចំកិច្ចពិគ្រោះយោបល់ជាផ្លូវការ មុនពេលអនុវត្តគម្រោងដែលត្រូវបានស្នើឡើង។

**កិច្ចព្រមព្រៀងជាក់លាក់** តម្រូវឱ្យមានការចរចាឱ្យបានល្អិតល្អន់ ដើម្បីសម្រេចឱ្យបាននូវការឯកភាពគ្នាលើលក្ខខណ្ឌនៃគម្រោង ដែលត្រូវបានលើកស្នើឡើង ក្នុងចំណោមប្រទេសជាសមាជិកទាំងអស់ មុនពេលមានការប្រើប្រាស់ទឹក ដូចដែលត្រូវបានលើកស្នើឡើង។

ដំណើរការទាំងនេះក៏អនុវត្តចំពោះគម្រោងហេដ្ឋារចនាសម្ព័ន្ធទឹកមួយចំនួនផងដែរ ផ្អែកទៅតាមកត្តាកំណត់ចំនួនបី៖ ប្រភេទទន្លេ រដូវ និងវិសាលភាពនៃការប្រើប្រាស់ទឹក។

**ការអនុវត្តដំណើរការសហប្រតិបត្តិការ**

| ប្រភេទទន្លេ | រដូវ | វិសាលភាពនៃការប្រើប្រាស់ទឹក | ដំណើរការដែលចាំបាច់ត្រូវមាន |
|---|---|---|---|
| ទន្លេមេ | រដូវប្រាំង | រវាងអាងទន្លេ (ពីអាងទន្លេមេគង្គទៅអាងទន្លេណាមួយផ្សេងទៀត) | កិច្ចព្រមព្រៀងជាក់លាក់ |
| | | នៅក្នុងអាងទន្លេ (ក្នុងអាងទន្លេមេគង្គ) | ការពិគ្រោះយោបល់ជាមុន |
| | រដូវវស្សា | រវាងអាងទន្លេ (ពីអាងទន្លេមេគង្គទៅអាងទន្លេណាមួយផ្សេងទៀត) | ការពិគ្រោះយោបល់ជាមុន |
| | | នៅក្នុងអាងទន្លេ (ក្នុងអាងទន្លេមេគង្គ) | ការជូនដំណឹង |
| ដៃទន្លេ | ទាំងពីររដូវ | ទាំងរវាងអាងទន្លេ និងនៅក្នុងអាងទន្លេ | ការជូនដំណឹង |

ដំណើរការទាំងនេះ ត្រូវបានរៀបចំឡើងដើម្បីសម្រួលដល់កិច្ចសហប្រតិបត្តិការផ្នែកទឹករបស់ប្រទេសទាំងបួន ដើម្បីប្រើប្រាស់ធនធានទឹកឱ្យបានល្អសម្រាប់គោលបំណងនៃការអភិវឌ្ឍ ហើយក្នុងពេលជាមួយគ្នា កាត់បន្ថយផលប៉ះពាល់អវិជ្ជមានឆ្លងដែន ដែលអាចកើតមានឡើងលើបរិស្ថាន និងជីវភាពរស់នៅរបស់សហគមន៍តាមដងទន្លេ ឱ្យនៅតិចជាអប្បបរមា។

ពុំមានដំណើរការណាមួយក្នុងចំណោមដំណើរការទាំងនេះ មានគោលបំណងផ្តល់ការឯកភាព ឬបដិសេធគម្រោងដែលត្រូវបានលើកស្នើនោះឡើយ។

ឧទាហរណ៍ នៅក្នុងដំណើរការពិគ្រោះយោបល់ជាមុន លេខាធិការដ្ឋាន MRC និងប្រទេសដែលបានទទួលការជូនដំណឹង ធ្វើការវាយតម្លៃផលប៉ះពាល់ឆ្លងដែន ដែលអាចកើតឡើងដោយសារគម្រោងដែលបានស្នើឡើង ទៅលើវិស័យផ្សេងៗ ដូចជា វិស័យជលផល ជលសាស្ត្រ និងនាវាចរណ៍ និងលើកជាអនុសាសន៍ពីវិធានការ ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ដែលអាចកើតមានឡើង។ ប្រសិនបើមានការចាំបាច់ គណៈកម្មាធិការរួម អាចបន្តរយៈពេលលើសពី ៦ខែ ដើម្បីរៀបចំការពិគ្រោះយោបល់បន្ថែម។ ប្រសិនបើពុំមានដំណោះស្រាយ គណៈកម្មាធិការរួម អាចបញ្ជូនបន្តករណីនេះទៅក្រុមប្រឹក្សា MRC ដើម្បីធ្វើការដោះស្រាយ។

## នីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង គាំទ្រដល់កិច្ចពិគ្រោះយោបល់ថ្នាក់តំបន់ស្តីពីផែនការអភិវឌ្ឍន៍

ចាប់តាំងពីឆ្នាំ ១៩៩៥ រហូតដល់ចុងខែ មិថុនា ឆ្នាំ ២០១៨ MRC បានទទួលសំណើគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទឹកចំនួន ៥៩។ សំណើចំនួន ៥៥ ត្រូវបានដាក់សម្រាប់ការជូនដំណឹង ៤ សម្រាប់ការពិគ្រោះយោបល់ជាមុន និងពុំទាន់មានសំណើសម្រាប់កិច្ចព្រមព្រៀងដាក់លាក់ឡើយ។

ក្នុងចំណោមករណីជូនដំណឹងទាំង៥៥ មាន៥០ករណីគឺជាគម្រោងនៅដៃទន្លេ និង៥ទៀតនៅដងទន្លេមេ។ ៨០% នៃករណីទាំងនេះ គឺជាគម្រោងវារីអគ្គិសនី ហើយករណីដែលនៅសេសសល់ គឺជាករណីជូនដំណឹងសម្រាប់គម្រោងធារាសាស្ត្រ គម្រោងគ្រប់គ្រងទឹកជំនន់ និងគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត។ គម្រោងទាំងនេះរួមមាន គម្រោងវារីអគ្គិសនីរបស់ប្រទេសកម្ពុជា ដែលស្នើសាងសង់លើដៃទន្លេសេសានក្នុងឆ្នាំ ២០១០ សំណើឆ្នាំ ១៩៩៥ របស់ប្រទេសថៃ ដើម្បីសិក្សាពីផែនការបង្វែរទឹកចេញពីដៃទន្លេកុក និងទន្លេអ៊ីង នៃតំបន់អាងទន្លេចៅប្រាយ៉ា និងគម្រោងធារាសាស្ត្រខ្នាតធំរបស់ប្រទេសវៀតណាម នៅក្នុងខេត្តដាឡាក់ ដែលស្ថិតនៅភូមិភាគកណ្តាល ជាគម្រោងដែលត្រូវបានលើកស្នើឡើងក្នុងឆ្នាំ ២០០៥។





ករណីពិគ្រោះយោបល់ជាមុនទាំងបួន សុទ្ធតែពាក់ព័ន្ធជាមួយ គម្រោងវារីអគ្គិសនីនៅតាមដងទន្លេមេគង្គ មេ ក្នុងប្រទេសឡាវ៖ សាយ៉ាប៊ូរី (២០១០) ដនសាហុង (២០១៣) ប៉ាក់បេង (២០១៦) និង ប៉ាក់ឡាយ (២០១៨)។ ករណីចំនួនបី បានបញ្ចប់ការពិគ្រោះយោបល់ជាមុនរយៈពេល ៦ខែ ដោយមានការវាយតម្លៃបច្ចេកទេសលម្អិត និងការពិគ្រោះយោបល់ជាសាធារណៈ។ នៅក្នុងករណីចំនួនពីរដំបូង សម្រាប់ទំនប់សាយ៉ាប៊ូរី និងដនសាហុង ពុំមានការឈានទៅដល់ដំណោះស្រាយជាផ្លូវការឡើយ នៅចុងដំណើរការនោះ។ នៅក្នុងករណីទំនប់ប៉ាក់បេង ដែលជាករណីទី ៣ ប្រទេសទាំងបួនបានចេញសេចក្ដីថ្លែងការណ៍រួមគ្នា អំពាវនាវឱ្យរដ្ឋាភិបាលឡាវ ខិតខំប្រឹងប្រែងឱ្យអស់លទ្ធភាព ដើម្បីបញ្ចៀស កាត់បន្ថយជាអតិបរមា និងសម្រាលផលប៉ះពាល់អវិជ្ជមានឆ្លងដែនលើលំហូរទឹក កំណល្បាប់ ប្រកធ្វើដំណើររបស់ត្រី ការធ្វើនាវាចរណ៍ និងស្ថានភាពសង្គម សេដ្ឋកិច្ច និងស្នើឱ្យលេខាធិការដ្ឋាន MRC រៀបចំផែនការសកម្មភាពសម្រាប់ដំណើរការក្រោយកិច្ចពិគ្រោះយោបល់។ ការពិគ្រោះយោបល់ជាមុន សម្រាប់ទំនប់ប៉ាក់ឡាយ នឹងធ្វើឡើងបន្ទាប់ពីការដាក់សំណើក្នុងខែ មិថុនា ឆ្នាំ ២០១៨។

ការពិគ្រោះយោបល់ជាមុនទាំងនេះ គឺជាករណីសាកល្បង សម្រាប់កិច្ចការទូតផ្នែកទឹករបស់ MRC។ ដំណើរការនេះ ផ្ដល់ឱកាសឱ្យប្រទេសដែលទទួលបានការជូនដំណឹងអង្គុយរួមគ្នា និងលើកឡើងពីការព្រួយបារម្ភរបស់ពួកគេ ជុំវិញផលប៉ះពាល់ឆ្លងដែន ផ្អែកតាមការវិភាគវិទ្យាសាស្ត្រ និងដើម្បីឱ្យភាគីពាក់ព័ន្ធដទៃទៀតផ្ដល់យោបល់ និងលើកជាសំណូមពរនានា។ ជាមួយនឹងនីតិវិធីសម្រាប់ការជូនដំណឹងការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង ព្រមទាំងយន្តការការទូតផ្នែកទឹកដទៃទៀត MRC នៅតែបំពេញតួនាទីយ៉ាងសំខាន់ ដើម្បីសម្រេចឱ្យបាននូវការអភិវឌ្ឍប្រកបដោយតុល្យភាព និងនិរន្តរភាពក្នុងតំបន់នេះ។

PMFM

## ការរក្សាលំហូរទឹកឱ្យបានល្អប្រសើរក្នុងទន្លេមេគង្គ និងទន្លេសាប

ការប្រែប្រួលលំហូរទឹកតាមរដូវក្នុងទន្លេមេគង្គ មានសារៈសំខាន់យ៉ាងខ្លាំងចំពោះប្រព័ន្ធអេកូឡូស៊ីរបស់តំបន់អាងទន្លេ និងជីវភាពរស់នៅរបស់ប្រទេសតាមដងទន្លេ។ ប្រសិនបើពុំមានទឹកជំនន់ប្រចាំឆ្នាំនោះទេ ត្រីនឹងមិនផ្លាស់ទីពីតំបន់អាងទឹកជ្រៅទៅតំបន់វាលទំនាប ដើម្បីពងនោះឡើយ។ ការរក្សាទឹកជំនន់គាំទ្រដល់ប្រព័ន្ធធារាសាស្ត្រនៅរដូវប្រាំង ខណៈពេលដែលដីល្បាប់ដែលហូរមកតាមទឹកជំនន់ ជួយបន្ថែមជីជាតិដីកាន់តែល្អប្រសើរជាងមុន។ ទឹកជំនន់ក៏ហូរនាំទឹកដែលដក់នៅមួយកន្លែង និងទឹកដែលត្រូវបានបំពុលទៅជាមួយផងដែរ។ ជាការសំខាន់ណាស់ ដែលប្រព័ន្ធអេកូឡូស៊ីរបស់ទន្លេមេគង្គ និងការប្រកបមុខរបរចិញ្ចឹមជីវិតនៅតាមដងទន្លេនេះ ត្រូវរក្សាលំហូរធម្មជាតិរបស់ទន្លេនេះ ជាពិសេសទប់ទល់នូវសម្ពាធពីការវិនិយោគដ៏ច្រើនលើធនធានទឹក និងការប្រែប្រួលអាកាសធាតុ។

ជាការឆ្លើយតប MRC និងប្រទេសជាសមាជិកបានរៀបចំ នីតិវិធីសម្រាប់រក្សាលំហូរទឹកនៅលើដងទន្លេមេ (ដែលហៅកាត់ថា PMFM) ដោយបានដាក់ចេញនូវក្របខ័ណ្ឌសម្រាប់រក្សាកម្រិតអប្បបរមា ឬអតិបរមានៃលំហូរទឹកក្នុងដងទន្លេមេគង្គមេ និងការហូរបញ្ច្រាស់មកវិញពីទន្លេសាបរបស់ប្រទេសកម្ពុជា ដែលភ្ជាប់ទន្លេមេគង្គមេទៅបឹងទន្លេសាប។ ការហូរបញ្ច្រាស់នេះគឺជាបាតុភូតពិសេសដែលកើតមានក្នុងរដូវទឹកជំនន់ ដែលទឹកក្នុងទន្លេសាបហូរត្រលប់ក្រោយ និងរុញច្រានទឹកដែលនៅសេសសល់ឱ្យចូលទៅក្នុងបឹង ដែលនាំឱ្យបឹងនេះពង្រីកខ្លួនដល់ទៅ ៦ ដង ជាងទំហំធម្មតារបស់វា។ អនុម័តក្នុងខែ មិថុនា ឆ្នាំ ២០០៦ នីតិវិធីសម្រាប់រក្សាលំហូរទឹកក្នុងដងទន្លេមេ ដាក់ចេញនូវលក្ខណៈវិនិច្ឆ័យបច្ចេកទេស ដើម្បីវាយតម្លៃពីកម្រិតគ្រប់គ្រាន់នៃលំហូរទឹក ដើម្បីការពារលំហូរទឹកតាមរដូវដែលមានលក្ខណៈពិសេសបែបនេះ ទប់ទល់នឹងការបង្វែរទឹក ការបញ្ចេញទឹកដែលស្តុកក្នុងអាងស្តុកទឹក និងសកម្មភាពផ្សេងទៀត ដែលអាចបង្កផលប៉ះពាល់គួរឱ្យកត់សម្គាល់ដល់ទន្លេមេ។



# នីតិវិធីសម្រាប់រក្សាលំហូរទឹកតាមដងទន្លេមេ ជួយរក្សាលំហូរទឹក តាមរយៈលក្ខណៈវិនិច្ឆ័យសម្រាប់ធ្វើការវាយតម្លៃ

នីតិវិធីសម្រាប់រក្សាលំហូរទឹកលើដងទន្លេមេ និងពង្រាងឯកសារបច្ចេកទេសពាក់ព័ន្ធ កំណត់ពីលំហូរបីប្រភេទ ដែលត្រូវរក្សាតាមរដូវ៖

- លំហូរទឹកធម្មជាតិអប្បបរមាប្រចាំខែ ក្នុងទន្លេមេគង្គ នៅរដូវប្រាំង (ខែ ធ្នូ-ឧសភា)
- លំហូរទឹកអតិបរមាប្រចាំថ្ងៃរបស់ទន្លេមេគង្គក្នុងរដូវទឹកជំនន់ (ខែ កក្កដា-តុលា)
- លំហូរទឹកបញ្ច្រាស់ទិសរបស់ទន្លេសាបនៅរដូវវស្សា (ខែ មិថុនា–វិច្ឆិកា)

ឯកសារណែនាំទាំងនេះ តម្រូវឱ្យប្រទេស៖ (១) ពិនិត្យតាមដានលំហូរទឹកប្រចាំថ្ងៃ និង (២) វាយតម្លៃលើការប្រែប្រួលលំហូរទឹក សម្រាប់គម្រោងអភិវឌ្ឍន៍ទឹកដែលត្រូវបានលើកស្នើឡើង។

ក្របខ័ណ្ឌនីតិវិធីសម្រាប់រក្សាលំហូរទឹកលើដងទន្លេមេ បានដាក់ចេញនូវលក្ខណៈវិនិច្ឆ័យចំនួនប្រាំមួយ ដើម្បីវាយតម្លៃលំហូរទឹក លក្ខណៈវិនិច្ឆ័យចំនួនបី សម្រាប់ពិនិត្យតាមដាន និងលក្ខណៈវិនិច្ឆ័យបីទៀតសម្រាប់ការរៀបចំផែនការ។

**លក្ខណៈវិនិច្ឆ័យ សម្រាប់វាយតម្លៃលំហូរទឹក**

| ទន្លេ | រដូវ | ប្រភេទលំហូរទឹកដែលត្រូវរក្សា | លក្ខណៈវិនិច្ឆ័យវាយតម្លៃលើលំហូរទឹក | |
|---|---|---|---|---|
| | | | សម្រាប់ពិនិត្យតាមដាន | សម្រាប់រៀបចំផែនការ |
| ទន្លេមេគង្គ | រដូវប្រាំង | លំហូរអប្បបរមាប្រចាំខែ | លំហូរអប្បបរមាប្រចាំថ្ងៃ | លំហូរអប្បបរមាប្រចាំខែ |
| | រដូវទឹកជំនន់ | លំហូរទឹកខ្ពស់បំផុតអតិបរមាប្រចាំថ្ងៃ | លំហូរអតិបរមាប្រចាំថ្ងៃ | លំហូរអតិបរមាប្រចាំខែ |
| ទន្លេសាប | រដូវវស្សា | លំហូរបញ្ច្រាស់ | លំហូរប្រចាំថ្ងៃកន្លងមក នៅព្រែកក្តាម | លំហូរតាមរដូវកាល នៅខេត្តក្រចេះ |

# នីតិវិធីសម្រាប់រក្សាលំហូរទឹកតាមដងទន្លេមេ ផ្តល់លទ្ធភាពឱ្យមានការប្រកាសអាសន្នទាន់ពេលវេលា

នីតិវិធីសម្រាប់រក្សាលំហូរដងទន្លេមេ តម្រូវឱ្យប្រទេសជាសមាជិកទាំងបួនប្រមូលទិន្នន័យប្រចាំថ្ងៃអំពីលំហូរទឹក ដូចជា ការបញ្ចេញទឹក កម្ពស់ទឹក និងបរិមាណទឹក នៅស្ថានីយជលសាស្ត្រចំនួន ១២ តាមទន្លេមេគង្គ និងទន្លេសាប។ នៅរដូវវស្សា ទិន្នន័យទាំងនេះត្រូវបានបញ្ជូនទៅលេខាធិការដ្ឋាន MRC ជារៀងរាល់ថ្ងៃ សម្រាប់បូកសរុប និងវិភាគ ដែលក្នុងនោះស្ថានភាពលំហូរទឹកប្រចាំថ្ងៃត្រូវបានដាក់ចំណាត់ថ្នាក់ថា “ធម្មតា” “មានស្ថិរភាព” “ពុំមានស្ថិរភាព” ឬ “ធ្ងន់ធ្ងរ” និងធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញ លើគេហទំព័រនៃនីតិវិធីសម្រាប់រក្សាលំហូរទឹកតាមដងទន្លេមេរបស់ MRC ដើម្បីឱ្យសាធារណជនទូទៅអាចចូលមើលបាន។ នៅរដូវប្រាំង ការប្រមូលទិន្នន័យលំហូរទឹក ត្រូវបានធ្វើឡើងជារៀងរាល់ថ្ងៃ ប៉ុន្តែបញ្ជូនទៅលេខាធិការដ្ឋាន MRC ជារៀងរាល់សប្តាហ៍។

ប្រសិនបើស្ថានភាព “ពុំមានស្ថិរភាព” ឬ “ធ្ងន់ធ្ងរ” MRC ជូនដំណឹងដល់ប្រទេសដែលពាក់ព័ន្ធ ដើម្បីចាត់វិធានការដែលចាំបាច់ និងផ្តល់ការគាំទ្របច្ចេកទេស ដើម្បីសម្រាលផលប៉ះពាល់នៅពេលចាំបាច់។

គិតរហូតមកដល់ពេលបច្ចុប្បន្ននេះ លំហូរទឹកទន្លេក្នុងទន្លេមេគង្គ និងទន្លេសាប ភាគច្រើននៅមានស្ថានភាពធម្មតា និងមានស្ថិរភាពពេញមួយឆ្នាំ។ មានតែករណីមួយប៉ុណ្ណោះ ដែលត្រូវបានកត់ត្រាថាជាស្ថានភាពធ្ងន់ធ្ងរ។ ហេតុការណ៍នោះកើតឡើងនៅដើមឆ្នាំ ២០១០ នៅពេលដែលរដូវមូសុងឆ្នាំ ២០០៩ បញ្ចប់ ៦ សប្តាហ៍ មុនពេលធម្មតា ហើយរដូវមូសុងឆ្នាំ ២០១០ ចាប់ផ្តើម ៤ សប្តាហ៍



យឺតជាងធម្មតា។ ស្ថានភាពគ្រោះរាំងស្ងួតធ្ងន់ធ្ងរ ត្រូវបានសង្កេតឃើញនៅតាមស្ថានីយពិនិត្យតាមដានភាគច្រើន។ ការវាយតម្លៃបានបង្ហាញថា ការគ្រប់គ្រងទឹកបន្តគ្នានៅតាមទំនប់វារីអគ្គិសនីក្នុងទន្លេមេគង្គលើ អាចរួមចំណែកបង្កគ្រោះរាំងស្ងួតដល់តំបន់នេះ។ ប្រទេសទាំងបួន បានទទួលការជូនដំណឹង ដើម្បីចាត់វិធានការកាត់បន្ថយផលប៉ះពាល់នេះ។

## នីតិវិធីសម្រាប់រក្សាលំហូរទឹកក្នុងដងទន្លេមេ នាំឱ្យមានការរៀបចំផែនការដោយអនុលោមតាមលំហូរទឹក

ក្របខ័ណ្ឌនៃនីតិវិធីសម្រាប់រក្សាលំហូរទឹកនៅតាមដងទន្លេមេ ក៏គាំទ្រឱ្យមានការរៀបចំផែនការអភិវឌ្ឍន៍ធនធានទឹកឱ្យរឹតតែប្រសើរផងដែរ។ នៅពេលផែនការអភិវឌ្ឍន៍មួយត្រូវបានលើកស្នើឡើង គេអាចព្យាករណ៍ពីការប្រែប្រួលនៃលំហូរទឹក តាមរយៈការគណនា ការរក្សាទុកទឹក ការបញ្ចេញទឹក និងវាយតម្លៃធៀបនឹងលក្ខណៈវិនិច្ឆ័យវាយតម្លៃលើលំហូរទឹក។ ប្រសិនបើលំហូរទឹកដែលត្រូវបានព្យាករណ៍ ពុំអាចទទួលយកបាននោះទេ មានការផ្តល់ជាអនុសាសន៍ពីដំណោះស្រាយ ដល់ប្រទេសដែលលើកសំណើឡើង ដើម្បីសម្រាលផលប៉ះពាល់ ដែលអាចកើតមានឡើង។

ការធ្វើតេស្តលើភាពអនុលោមបែបនេះ ត្រូវបានប្រើប្រាស់សម្រាប់គម្រោងវារីអគ្គិសនីសាយ៉ាប៊ូរី ដនសាហុង និងប៉ាក់បេង ក្នុងប្រទេសឡាវ ក្នុងអំឡុងដំណើរការពិគ្រោះយោបល់ជាមុន។ កម្រិតលំហូរទឹកដែលបានព្យាករណ៍ សុទ្ធតែត្រូវបានរកឃើញថាអាចទទួលយកបាន ដោយសារតែ សមត្ថភាពស្តុកទឹកនៅមានកម្រិត ហើយការរៀបចំ និងប្រតិបត្តិការទំនប់ទាំងនេះ ធ្វើឡើងជាប្រភេទគម្រោងទំនប់មិនបង្កើតជាអាងទឹក។ តេស្តនេះក៏ត្រូវបានធ្វើឡើងចំពោះសេណារីយ៉ូអភិវឌ្ឍន៍ ក្នុងតំបន់អាងទន្លេទាំងមូល ដែលមានផែនការគម្រោងអភិវឌ្ឍន៍ជាបន្តបន្ទាប់ផងដែរ។ នីតិវិធីសម្រាប់រក្សាលំហូរទឹកលើដងទន្លេមេ បានរួមចំណែកនាំឱ្យមានការកំណត់ស្តង់ដាការវាយតម្លៃលំហូរទឹកក្នុងតំបន់អាងទន្លេទាំងមូល។

| ចំណាត់ថ្នាក់នៃស្ថានភាពលំហូរទឹក | | | |
|---|---|---|---|
| ល្អ | មធ្យម | ខ្សោយ | ខ្សោយខ្លាំង |

[ផែនទី] ស្ថានីយជលសាស្ត្រ សម្រាប់ពិនិត្យតាមដានលំហូរទឹក



PWQ

## ការការពារគុណភាពទឹកក្នុងទន្លេមេគង្គ

គុណភាពទឹកទាប អាចគំរាមកំហែងដល់សុខភាពរបស់មនុស្ស និងស្ថានភាពនៃប្រព័ន្ធអេកូឡូស៊ី។ ការការពារគុណភាពទឹកទន្លេមេគង្គឱ្យនៅល្អ មានសារៈសំខាន់សម្រាប់ប្រជាពលរដ្ឋក្នុងសហគមន៍តាមដងទន្លេ និងជីវិតវារីជាតិរបស់ទន្លេនេះ ដោយសារតែមនុស្សជាង ៦៥ លាននាក់ ពឹងអាស្រ័យលើធនធានទឹកក្នុងទន្លេមេគង្គក្រោម សម្រាប់ជាអាហារ និងរកចំណូល។

ជាការឆ្លើយតបចំពោះភាពចាំបាច់ក្នុងការពិនិត្យតាមដាន និងការពារគុណភាពទឹកក្នុងតំបន់អាងទន្លេមេគង្គក្រោម MRC និងប្រទេសជាសមាជិកបានរៀបចំនីតិវិធីសម្រាប់គុណភាពទឹក (ដែលហៅកាត់ថា PWQ) ជាក្របខ័ណ្ឌសហប្រតិបត្តិការមួយ ដែលធានាឱ្យមានការរក្សាគុណភាពទឹកក្នុងទន្លេមេគង្គ និងដៃទន្លេសំខាន់ៗរបស់ទន្លេនេះ ក្នុងកម្រិតដែលអាចទទួលយកបាន។ អនុម័តក្នុងខែ មករា ឆ្នាំ ២០១១ នីតិវិធីសម្រាប់គុណភាពទឹក និងឯកសារបច្ចេកទេសដែលពាក់ព័ន្ធ ដាក់ចេញនូវលក្ខណៈវិនិច្ឆ័យវាយតម្លៃសម្រាប់គ្រប់គ្រងគុណភាពទឹក។

## នីតិវិធីសម្រាប់គុណភាពទឹក ពង្រឹងការគ្រប់គ្រងគុណភាពទឹក

នីតិវិធីសម្រាប់គុណភាពទឹកកំណត់ពីសកម្មភាពចំនួនពីរប្រភេទ ដើម្បីរក្សាគុណភាពទឹក ក្នុងកម្រិតដែលអាចទទួលយកបានចំពោះមនុស្ស រុក្ខជាតិ និងសត្វ៖ (១) ការពិនិត្យតាមដានគុណភាពទឹក និង (២) ការឆ្លើយតបចំពោះស្ថានភាពអាសន្ន។ នីតិវិធីសម្រាប់គុណភាពទឹក អំពាវនាវឱ្យប្រទេសតាមដងទន្លេមេគង្គទាំងបួន ធ្វើការពិនិត្យតាមដានគុណភាពទឹកឱ្យបានជាប្រចាំក្នុងតំបន់អាងទន្លេទាំងមូល និងរៀបចំយន្តការឆ្លើយតបចំពោះស្ថានភាពបន្ទាន់ ដែលនាំឱ្យមានការបំពុលទឹក ដូចជា ការហៀរប្រេង និងការបញ្ចេញទឹកស្អុយ ដែលមានជាតិពុលជាដើម ដើម្បីការពារទន្លេនេះ និងកាត់បន្ថយផលប៉ះពាល់មកលើប្រព័ន្ធអេកូឡូស៊ី និងសហគមន៍ជុំវិញឱ្យនៅតិចជាអប្បបរមា។

ពាក់ព័ន្ធនឹងការពិនិត្យតាមដានគុណភាពទឹក នីតិវិធីសម្រាប់គុណភាពទឹក និងឯកសារណែនាំបច្ចេកទេស កំណត់ពីទីតាំង និងភាពញឹកញាប់នៃការប្រមូលទឹកសម្រាប់ធ្វើជាសំណាកគំរូ និងដាក់ចេញនូវលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃ និងកំណត់ពីតម្លៃគុណភាពទឹក សម្រាប់សុខភាពមនុស្ស និងជីវិតវារីជាតិ។ ការពិនិត្យតាមដានគុណភាពទឹកជាប្រចាំ គឺជាសកម្មភាពដែលធ្វើឡើងបន្ទាប់ពីសកម្មភាពពិនិត្យតាមដានក្នុងតំបន់អាងទន្លេ ដែលចាប់ផ្តើមក្នុងឆ្នាំ ១៩៨៥ ជាមួយនឹងបណ្តាញស្ថានីយប្រមូលសំណាកគំរូក្នុងតំបន់អាងទន្លេមេគង្គក្រោម។

# នីតិវិធីសម្រាប់គុណភាពទឹក ដាក់ពិន្ទុលើគុណភាព

ក្រោមក្របខ័ណ្ឌនៃនីតិវិធីសម្រាប់គុណភាពទឹក បច្ចុប្បន្ននេះ ប្រទេសជាប់ទន្លេមេគង្គទាំងបួនធ្វើការប្រមូលសំណាកគំរូគុណភាពទឹកពីស្ថានីយប្រមូលសំណាកគំរូចំនួន ៤៨ ក្នុងនោះ មាន ១៧ ស្ថានីយ លើដងទន្លេមេ ៥ស្ថានីយ នៅលើដៃទន្លេមេ គឺទន្លេបាសាក់ និងស្ថានីយដែលនៅសេសសល់ស្ថិតនៅលើដៃទន្លេផ្សេងទៀត។

នៅតាមស្ថានីយនីមួយៗ មានការវិភាគប៉ារ៉ាម៉ែត្រគុណភាពទឹកចំនួន ១២ (សីតុណ្ហភាព កម្រិត pH កម្រិតជាតិប្រៃកម្រិតអាស៊ីដ ។ល។)ជារៀងរាល់ខែ ហើយប៉ារ៉ាម៉ែត្រចំនួន ៦ ទៀត(កាល់ស្យូមម៉ាញេស្យូម សូដ្យូម។ល។) ត្រូវបានពិនិត្យនៅរដូវវស្សា ចាប់ពីខែ មេសា ដល់ខែ តុលា។ តម្រូវការអ៊ុកស៊ីហ្សែនគីមីជីវសាស្ត្រ ដែលជាប៉ារ៉ាម៉ែត្រមួយទៀត ត្រូវបានវាយតម្លៃជារៀងរាល់ខែនៅតាមស្ថានីយ ដែលត្រូវបានជ្រើសរើសមួយចំនួនតូច ពេញមួយឆ្នាំ។ បន្ទាប់ពីការវាយតម្លៃលើគុណភាពរួចហើយ សំណាកគំរូត្រូវបានចាត់ចំណាត់ថ្នាក់ថា “ល្អបំផុត” “ល្អ” “មធ្យម” “ទាប” ឬ “ទាបខ្លាំង” សម្រាប់សុខភាពមនុស្ស និងចំណាត់ថ្នាក់ ៥ ស្រដៀងគ្នានេះផ្សេងទៀត សម្រាប់ជីវិតវារីជាតិ។ សំណាកគំរូទាំងនេះ ក៏ត្រូវបានវិភាគសម្រាប់ការប្រើប្រាស់ទឹកក្នុងប្រព័ន្ធធារាសាស្ត្រផងដែរ។

ទិន្នន័យសំណាកគំរូទាំងនេះ ត្រូវបានផ្ញើទៅកាន់លេខាធិការដ្ឋាន MRC ជារៀងរាល់ឆ្នាំ ដើម្បីផ្ទៀងផ្ទាត់ និងរក្សាទុកក្នុងប្រព័ន្ធទិន្នន័យ ដើម្បីឱ្យសាធារណជនទូទៅអាចចូលមើលបាន។ លេខាធិការដ្ឋាន MRC បន្តរៀបចំរបាយការណ៍បូកសរុបប្រចាំឆ្នាំ ដែលមានចំណងជើងថា *របាយការណ៍ពិនិត្យតាមដានគុណភាពទឹកនៅតំបន់ទន្លេមេគង្គក្រោម* ផ្អែកតាមទិន្នន័យដែលប្រមូលបានពីស្ថានីយសំខាន់ៗទាំង ២២ នៅលើដងទន្លេមេគង្គ និងទន្លេបាសាក់។



| ចំណាត់ថ្នាក់គុណភាពទឹក | | | | | |
|---|---|---|---|---|---|
| ជីវិតវារីជាតិ | ខ្ពស់ | ល្អ | មធ្យម | ទាប | ទាបខ្លាំង |
| សុខភាពមនុស្ស | ល្អបំផុត | ល្អ | មធ្យម | ទាប | ទាបខ្លាំង |

នៅក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ MRC បានប្រមូលសំណុំទិន្នន័យទាន់ពេលវេលា អំពីគុណភាពទឹកក្នុងទន្លេមេគង្គ និងដៃទន្លេនេះ។ ទិន្នន័យទាំងនេះ ផ្តល់លទ្ធភាពឱ្យប្រទេសជាប់ដងទន្លេមេគង្គកំណត់ពីការប្រែប្រួលគុណភាពទឹក ដើម្បីចាត់វិធានការបង្ការ និងកែតម្រូវ និងងាយស្រួលកំណត់ពីការបំពុលទឹកឆ្លងដែន។ ទិន្នន័យនេះ ក៏ផ្តល់នូវប្រព័ន្ធទិន្នន័យមូលដ្ឋានដ៏មានប្រយោជន៍ សម្រាប់សិក្សាពីផលប៉ះពាល់ដែលអាចកើតមានឡើងលើការអភិវឌ្ឍផងដែរ។ បើតាមរបាយការណ៍ប្រចាំឆ្នាំ គុណភាពទឹកទន្លេមេគង្គជារួម នៅមានភាពល្អប្រសើរក្នុងតំបន់អាងទន្លេទាំងមូល លើកលែងតែបញ្ហាដោយឡែកៗមួយចំនួននៅតំបន់ ដែលមានប្រជាពលរដ្ឋរស់នៅកកកុញ និងពុំមានភស្តុតាងដែលបង្ហាញពីការបំពុលឆ្លងដែននោះឡើយ។

(ផែនទី) ស្ថានីយពិនិត្យតាមដានគុណភាពទឹក



## នីតិវិធីសម្រាប់គុណភាពទឹក ខិតខំជំរុញឱ្យមានការឆ្លើយតបជារួមចំពោះស្ថានភាពអាសន្ននៃការបំពុលទឹក

សម្រាប់ការគ្រប់គ្រងស្ថានភាពអាសន្ននៃការបំពុលទឹកវិញ នីតិវិធីសម្រាប់គុណភាពទឹកតម្រូវឱ្យប្រទេសមេគង្គទាំងបួនរៀបចំផែនការបម្រុង ដើម្បីឆ្លើយតបចំពោះស្ថានភាពអាសន្នឆ្លងដែន និងបង្កើតយន្តការក្នុងតំបន់អាងទន្លេទាំងមូល ដើម្បីធ្វើការសម្របសម្រួលសកម្មភាពនានា។ បើទោះបីជាពុំមានករណីបំពុលឆ្លងដែនកន្លងមកយ៉ាងណាក៏ដោយ ប្រទេសជាប់ទន្លេមេគង្គ មើលឃើញពីសារៈសំខាន់នៃការរៀបចំការឆ្លើយតបរួមគ្នាក្នុងតំបន់អាងទន្លេទាំងមូល ដើម្បីអាចគ្រប់គ្រងគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព។

ចាប់តាំងពីមានការអនុម័តលើនីតិវិធីសម្រាប់គុណភាពទឹករួចមក ប្រទេសមេគង្គទាំងបួនបានចរចាដំណើរការនៅថ្នាក់ជាតិ និងថ្នាក់តំបន់ ដើម្បីគ្រប់គ្រងស្ថានភាពអាសន្ននៃការបំពុលទឹក និង បានរៀបចំឯកសារបច្ចេកទេសឆ្នាំ ២០១៦ សម្រាប់បង្កើតនូវប្រព័ន្ធឆ្លើយតប និងគ្រប់គ្រងស្ថានភាពអាសន្ន។ ឯកសារណែនាំនេះ ទទួលស្គាល់យន្តការដែលមានស្រាប់ សម្រាប់ឆ្លើយតបចំពោះស្ថានភាពអាសន្ននៃគ្រោះមហន្តរាយធម្មជាតិ ក្រោមក្របខ័ណ្ឌសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) និងបានកត់សម្គាល់ថា បច្ចុប្បន្ននេះកំពុងមានការពង្រីកយន្តការទាំងនេះ ដើម្បីគ្របដណ្តប់លើគ្រោះមហន្តរាយដែលបង្កឡើងដោយមនុស្ស តួយ៉ាងការបំពុលទឹកជាដើម។ ដើម្បីបញ្ចៀសមិនឱ្យមានការបង្កើតការឆ្លើយតបចំពោះស្ថានភាពអាសន្នពីរស្របគ្នាក្នុងតំបន់អាងទន្លេនេះ MRC មានគោលបំណងសហការជាមួយអាស៊ាន ដើម្បីរៀបចំយន្តការឆ្លើយតបចំពោះស្ថានភាពអាសន្ននៅថ្នាក់តំបន់ដែលអាចបំពេញទៅតាមតម្រូវការ នៃការគ្រប់គ្រងគុណភាពទឹក ក្នុងពេលមានគ្រោះមហន្តរាយនៅថ្នាក់ជាតិ ឆ្លងដែន និងថ្នាក់តំបន់។



# សម្រាប់ព័ត៌មានបន្ថែម

## វិធាននីតិវិធីរបស់ MRC ទំព័រទី ៣

- កិច្ចព្រមព្រៀងមេគង្គឆ្នាំ ១៩៩៥ និងនីតិវិធី MRC (អត្ថបទទាំងស្រុង)៖ *http://www.mrcmekong.org/assets/Publications/MRC-1995-Agreement-procedures-update-2017*

## នីតិវិធីសម្រាប់ការដោះដូរ និងការចែករំលែកទិន្នន័យ និងព័ត៌មាន (**PDIES**) ទំព័រទី ៦

- ផតថលសេវាទិន្នន័យ និងព័ត៌មាន៖ *portal.mrcmekong.org*
- MekongInfo៖ *www.mekonginfo.org*
- វេទិកាសហគមន៍៖ *community.mrcmekong.org*
- ប្រព័ន្ធទិន្នន័យសង្គមសេដ្ឋកិច្ចរបស់ MRC៖ *sedb.mrcmekong.org*

## នីតិវិធីសម្រាប់ការពិនិត្យតាមដានការប្រើប្រាស់ទឹក (**PWUM**) ទំព័រទី ១០

- នីតិវិធីសម្រាប់ការពិនិត្យតាមដានការប្រើប្រាស់ទឹក (PWUM)៖ *www.mrcmekong.org/assets/Uploads/Tech-Guidelines-PWUM.pdf*

## នីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង (**PNPCA**) ទំព័រទី ១៤

- នីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង៖ *www.mrcmekong.org/assets/Publications/policies/Guidelines-on-implementation-of-the-PNPCA.pdf*
- ខិតប័ណ្ណអំពីនីតិវិធី PNPCA៖ *www.mrcmekong.org/assets/Publications/PNPCA-brochure-11th-design-final.pdf*
- ការពិគ្រោះយោបល់ជាមុននៃនីតិវិធី PNPCA៖ *www.mrcmekong.org/topics/pnpca-prior-consultation*

## នីតិវិធីសម្រាប់រក្សាលំហូរទឹកក្នុងដងទន្លេមេ (**PMFM**) ទំព័រទី ១៨

- ⓘ នីតិវិធីសម្រាប់រក្សាលំហូរទឹកក្នុងដងទន្លេមេ (PMFM)៖ *www.mrcmekong.org/assets/Publications/policies/Procedures-Maintenance-Flows.pdf*
- ⓘ គេហទំព័រនៃនីតិវិធី PMFM៖ *pmfm.mrcmekong.org*

## នីតិវិធីស្រមាប់គុណភាពទឹក (**PWQ**) ទំព័រទី ២២

- ⓘ នីតិវិធីសម្រាប់គុណភាពទឹក៖ *www.mrcmekong.org/about-mrc/mandate/procedures-for-water-quality*
- ⓘ ប្រព័ន្ធទិន្នន័យគុណភាពទឹក៖ *portal.mrcmekong.org/waterquality_map*
- ⓘ របាយការណ៍គុណភាពទឹកប្រចាំឆ្នាំ៖ *www.mrcmekong.org/assets/Publications/2016-Lower-Mekong-Regional-Water-Quality-Monitoring-Report-14June18-L-Res.pdf*

លេខាធិការដ្ឋាន MRC
អគារលេខ ១៨៤ ផ្លូវ Fa Ngoum ប្រអប់សំបុត្រ
៦១០១ ទីក្រុងវៀងច័ន្ទ សាធារណៈរដ្ឋ
ប្រជាធិបតេយ្យប្រជាមានិតឡាវ
ទូរស័ព្ទ៖ +៨៥៦ ២១ ២៦៣ ២៦៣
ទូរសារ៖ +៨៥៦ ២១ ២៦៣ ២៦៤
អ៊ីម៉ែល៖ mrcs@mrcmekong.org
www.mrcmekong.org

ឯកសារបោះពុម្ពផ្សាយនេះមានគោលបំណងប្រើប្រាស់ជាព័ត៌មានសាធារណៈតែប៉ុណ្ណោះ។ ឯកសារនេះមិនគួរចាត់ទុកជាឯកសារនីតិវិធីផ្លូវការរបស់ MRC ឡើយ។

© គណៈកម្មការទន្លេមេគង្គ
បោះពុម្ពផ្សាយក្នុងខែ កក្កដា ឆ្នាំ ២០១៨